# កិច្ចតែងការបង្រៀន

- មុខវិជ្ជា ៖ រូបវិទ្យា
- ថ្នាក់ទី ៖ ៩
- ជំពូកទី១ ៖ ផលរង្វិល នៃកម្លាំង
- មេរៀនទី២ ៖ ម៉ូម៉ង់នៃកម្លាំង
- រយៈពេល ៖ ១ម៉ោង (៥០នាទី)
- ម៉ោងទី ៖ ២

## I- វត្ថុបំណង

- ចំណេះដឹង៖ រៀបរាប់ពីកត្តានៃលក្ខខណ្ឌលំនឹង នៃអង្គធាតុមួយចល័តជុំវិញអ័ក្សមួយ បានត្រឹមត្រូវតាមរយៈការពិសោធន៍។
- បំណិន៖ រកឃើញពីលក្ខណៈនៃលំនឹងរបស់អង្គធាតុមួយ ចល័តជុំវិញអ័ក្សមួយបានត្រឹមត្រូវតាមរយៈការពិសោធន៍។
- ឥរិយាបថ៖ មានបម្រុងប្រយ័ត្នក្នុងការគិតលេខ នៅពេលកំពុងធ្វើលំហាត់។

## II- សម្ភារៈបង្រៀន និងរៀន

**ឯកសារយោង៖**

+ សៀវភៅពុម្ពសិស្សថ្នាក់ទី៩ មុខវិជ្ជារូបវិទ្យា របស់ក្រសួងអប់រំ យុវជន និងកីឡា ទំព័រទី៨ ដល់ទំព័រទី៩ បោះពុម្ពឆ្នាំ ២០១៣។
+ សៀវភៅពុម្ពគ្រូថ្នាក់ទី៩ មុខវិជ្ជារូបវិទ្យា របស់ក្រសួងអប់រំ យុវជន និងកីឡា។
+ សៀវភៅណែនាំគ្រូរបស់ STEPSAM3 ទំព័រទី៥៣ ដល់ទំព័រទី៥៤។

**សម្ភារៈបង្រៀន និងរៀន**

+ របា កូនទម្ងន់ ខ្សែ...។

## III- សកម្មភាពបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| <u>ត្រួតពិនិត្យ</u><br>- អនាម័យ<br>-សណ្តាប់ធ្នាប់<br>-អវត្តមាន ។ | ជំហានទី១ (២ ឬ៣នាទី)<br>**រដ្ឋបាលថ្នាក់** | ប្រធាន ឬអនុប្រធានថ្នាក់ ជួយសម្របសម្រួលឡើងរាយការណ៍ ពីអវត្តមានសិស្ស។ |

<table>
<tr>
<td>- គ្រូសួរសំណួរៈ<br>- ដូចម្តេច ដែលហៅថា ម៉ូម៉ង់នៃកម្លាំង?<br>- ចូរសរសេររូបមន្តរបស់ម៉ូម៉ង់។</td>
<td>ជំហានទី២ (១០នាទី)<br>រំឭកមេរៀនចាស់</td>
<td>- សិស្សឆ្លើយសំណួរៈ<br>- ម៉ូម៉ង់នៃកម្លាំង គឺជាផលគុណរវាងកម្លាំង និងប្រវែងដៃឃ្នាស់។<br>- សរសេររូបមន្តរបស់ម៉ូម៉ង់៖<br>$M = F \times d$</td>
</tr>
<tr>
<td>- គ្រូសរសេរចំណងជើងមេរៀនដាក់នៅលើក្តាខៀន ។<br>- អោយសិស្សម្នាក់ ស្ម័គ្រចិត្តឡើងអានមេរៀន។<br>- គ្រូមាន របា កូនទម្ងន់ ខ្សែ តាមរូបភាពនេះ។ ចូរប្អូនសាកល្បងទាយថា តើរបានេះមានលំនឹងដែរឬទេ នៅពេលព្យួរកូនទម្ងន់ទាំងពីរ នៅអ័ក្សខាងស្តាំមួយ និងខាងឆ្វេងមួយ?</td>
<td>ជំហានទី៣៖ មេរៀនថ្មី (៣០នាទី)<br>ជំពូកទី១៖ ផលរង្វិលនៃកម្លាំង<br>មេរៀនទី២៖ ម៉ូម៉ង់នៃកម្លាំង<br>៣. លក្ខខណ្ឌលំនឹងនៃអង្គធាតុមួយចល័តជុំវិញអ័ក្ស<br><br><br>ក. សំណួរគន្លឹះ</td>
<td>-សិស្សកត់ចំណងជើងមេរៀន ចូលទៅក្នុងសៀវភៅ។<br>- សិស្សម្នាក់ស្ម័គ្រចិត្តឡើងអានមេរៀន។<br>- សិស្សសង្កេតរូបភាព រួចឆ្លើយទៅតាមការយល់ឃើញអាចជា មានលំនឹង ឬ គ្មានលំនឹង។</td>
</tr>
<tr>
<td colspan="3">តើអង្គធាតុមួយចល័តជុំវិញអ័ក្សមួយ មានលំនឹងបានយ៉ាងដូចម្តេច?</td>
</tr>
<tr>
<td>- គ្រូចែកសិស្សជាបួនក្រុមពិភាក្សា និងធ្វើពិសោធន៍។<br>- ចូរប្អូនធ្វើពិសោធន៍របស់យើងមានពីរ គឺពាក់ព័ន្ធនឹង ប្រវែងរបា និងទំហំរបស់កូនទម្ងន់។<br><br>- គ្រូណែនាំសិស្សអោយជ្រើសរើសឧបករណ៍ពិសោធន៍។</td>
<td>ខ. សម្មតិកម្ម<br>- សម្ភារៈមាន កូនទម្ងន់តូចធំ របាវែងខ្លី។<br>គ. ពិសោធន៍<br>- យកខ្សែចងរបា រួចយកកូនទម្ងន់ពីរ (តូច, ធំ) ព្យួរលើរបាម្តង និងម្តងទៀត។ កូនទម្ងន់ពីរស្មើរគ្នា ហើយសង្កេតទៅលើភាពខុសគ្នា។<br>ឃ. លទ្ធផលពិសោធន៍<br>- ដាក់កូនទម្ងន់លើរបា ដែលស្ថិតនៅ</td>
<td>- សិស្សចូលទៅតាមក្រុមពិភាក្សា និងធ្វើពិសោធន៍។<br>- យកខ្សែចងរបា រួចយកកូនទម្ងន់ពីរ (តូច, ធំ) ព្យួរលើរបាម្តង និងម្តងទៀត។ កូនទម្ងន់ពីរស្មើរគ្នា ហើយសង្កេតទៅលើភាពខុសគ្នា។<br><br>- កូនទម្ងន់ ស្ថិតនៅចម្ងាយស្មើគ្នា។</td>
</tr>
</table>

<table>
<tr>
<td>- គ្រូហៅសិស្សអោយឆ្លើយសំណួរគន្លឹះ។<br><br>- គ្រូហៅសិស្សឡើងសន្និដ្ឋាន។</td>
<td>ចម្ងាយស្មើគ្នា។
<table>
<tr><th>កូនទម្ងន់ (តូច, ធំ)</th><th>លំនឹងនៃរបា</th></tr>
<tr><td>តូច, ធំ</td><td>គ្មានលំនឹង</td></tr>
<tr><td>ស្មើគ្នា</td><td>មានលំនឹង</td></tr>
</table>
- ដាក់កូនទម្ងន់លើរបា ដែលស្ថិតនៅចម្ងាយខុសគ្នា។
<table>
<tr><th>កូនទម្ងន់ (តូច, ធំ)</th><th>លំនឹងនៃរបា</th></tr>
<tr><td>តូច, ធំ</td><td>មានលំនឹង</td></tr>
<tr><td>ស្មើគ្នា</td><td>គ្មានលំនឹង</td></tr>
</table>
- ទម្ងន់របស់កូនទម្ងន់ មានឥទ្ធិពលទៅលើលំនឹងរបស់របា មានន័យថា៖<br>
+ កូនទំម្ងន់ពីរដែល (តូច, ធំ) ធ្វើអោយរបាគ្មានលំនឹង។<br>
+ កូនទម្ងន់ពីរដែល (ស្មើគ្នា ) ធ្វើអោយរបាមានលំនឹង ។<br>
ង. សន្និដ្ឋាន<br>
- អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹងកាលណាផលបូកម៉ូម៉ង់នៃកម្លាំង ដែលមានអំពើអង្គធាតុនោះ ស្មើនឹងសូន្យ ឬម៉ូម៉ង់ (+) នៃអ័ក្សរង្វិលខាងស្តាំ ស្មើនឹង (-) នៃអ័ក្ស។</td>
<td><table>
<tr><th>កូនទម្ងន់ (តូច, ធំ)</th><th>លំនឹងនៃរបា</th></tr>
<tr><td>តូច, ធំ</td><td>គ្មានលំនឹង</td></tr>
<tr><td>ស្មើគ្នា</td><td>មានលំនឹង</td></tr>
</table>
- កូនទម្ងន់ ស្ថិតនៅចម្ងាយខុសគ្នា។
<table>
<tr><th>កូនទម្ងន់ (តូច, ធំ)</th><th>លំនឹងនៃរបា</th></tr>
<tr><td>តូច, ធំ</td><td>មានលំនឹង</td></tr>
<tr><td>ស្មើគ្នា</td><td>គ្មានលំនឹង</td></tr>
</table>
- ទម្ងន់របស់កូនទម្ងន់ មានឥទ្ធិពលទៅលើលំនឹងរបស់របា មានន័យថា៖<br>
+ កូនទំម្ងន់ពីរដែល (តូច, ធំ) ធ្វើអោយរបាគ្មានលំនឹង។<br>
+ កូនទម្ងន់ពីរដែល (ស្មើគ្នា ) ធ្វើអោយរបាមានលំនឹង ។<br><br>
- អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹងកាលណាផលបូកម៉ូម៉ង់នៃកម្លាំង ដែលមានអំពើអង្គធាតុនោះ ស្មើនឹងសូន្យ ឬម៉ូម៉ង់ (+) នៃអ័ក្សរង្វិលខាងស្តាំ ស្មើនឹង (-) នៃអ័ក្ស។</td>
</tr>
<tr>
<td>- តើអង្គធាតុមួយ ចល័តជុំវិញអ័ក្សមួយ មានលំនឹងបានយ៉ាងដូចម្តេច?<br><br>- តើអង្គធាតុមួយ ចល័តជុំវិញអ័ក្សមួយ មានលំនឹងបាននៅពេលណា?</td>
<td>ជំហានទី៤៖ ពង្រឹងចំណេះដឹង (៥នាទី)<br>
- អង្គធាតុមួយចល័ត ជុំវិញអ័ក្សមួយមានលំនឹងបាន អាស្រ័យលើទម្ងន់ និងប្រវែង។<br>
- អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹងកាលណាផលបូកម៉ូម៉ង់នៃកម្លាំង ដែលមានអំពើអង្គធាតុនោះ ស្មើនឹងសូន្យ ឬម៉ូម៉ង់ (+) នៃអ័ក្សរង្វិលខាងស្តាំ ស្មើនឹង (-) នៃអ័ក្ស។</td>
<td><br>- អង្គធាតុមួយចល័ត ជុំវិញអ័ក្សមួយមានលំនឹងបាន អាស្រ័យលើទម្ងន់ និងប្រវែង។<br>
- អង្គធាតុមួយចល័តជុំវិញអ័ក្សមួយមានលំនឹងកាលណាផលបូកម៉ូម៉ង់នៃកម្លាំង ដែលមានអំពើអង្គធាតុនោះ ស្មើនឹងសូន្យ ឬម៉ូម៉ង់ (+) នៃអ័ក្សរង្វិលខាងស្តាំ ស្មើនឹង (-) នៃអ័ក្ស។</td>
</tr>
</table>

| | | |
|---|---|---|
| - គ្រូចែកសន្លឹកលំហាត់ អោយសិស្សធ្វើនៅផ្ទះ។ | ជំហានទី៥ (៣នាទី)<br>**កិច្ចការផ្ទះ និងបណ្ដាំផ្ញើរ**<br>- <u>លំហាត់:</u> មនុស្សម្នាក់មានទម្ងន់ 600N អង្គុយលើចុងម្ខាង នៃដងថ្លឹងចម្ងាយ 1.5m ពីអ័ក្សរង្វិល ដើម្បីអោយដងថ្លឹងមានលំនឹង ស្ថិតតាមទិសដេក។ តើគេត្រូវដាក់មនុស្សម្នាក់ទៀត មានទម្ងន់ប៉ុន្មានអង្គុយនៅចុងម្ខាងទៀត នៃដងថ្លឹង ដែលមានប្រវែង 2m ពីអ័ក្សរង្វិល។<br><br><br>- <u>ចម្លើយ:</u> គណនាទម្ងន់របស់មនុស្សម្នាក់ទៀត ដែលត្រូវដាក់នៅចុងម្ខាងនៃដងថ្លឹង។<br>+ ម៉ូម៉ង់ខាងឆ្វេង: $M_1 = F_1 \times d_1$<br>$= 600N \times 1.5m$<br>$= 900N.m$<br>+ ម៉ូម៉ង់ខាងស្តាំ: $M_2 = F_2 \times d_2$<br>$= F_2 \times 2m$<br>$= 2F_2$<br>- ដើម្បីអោយរបាមានលំនឹង លុះត្រាតែម៉ូម៉ង់ទាំងពីរស្មើគ្នាគឺ $M_1 = M_2$<br>$900 = 2F_2$<br>⇨ $F_2 = \frac{900}{2} = 450$<br>- ដូចនេះ: $F_2 = 450N$ | - លំហាត់កិច្ចការផ្ទះ<br><br>- <u>ចម្លើយ:</u> គណនាទម្ងន់របស់មនុស្សម្នាក់ទៀត ដែលត្រូវដាក់នៅចុងម្ខាងនៃដងថ្លឹង។<br>+ ម៉ូម៉ង់ខាងឆ្វេង: $M_1 = F_1 \times d_1$<br>$= 600N \times 1.5m$<br>$= 900N.m$<br>+ ម៉ូម៉ង់ខាងស្តាំ: $M_2 = F_2 \times d_2$<br>$= F_2 \times 2m$<br>$= 2F_2$<br>- ដើម្បីអោយរបាមានលំនឹង លុះត្រាតែម៉ូម៉ង់ទាំងពីរស្មើគ្នាគឺ $M_1 = M_2$<br>$900 = 2F_2$<br>⇨ $F_2 = \frac{900}{2} = 450$<br>- ដូចនេះ: $F_2 = 450N$ |